ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ៧៣៩៩ ព.ណ......ស.ប.អ

ភ្នំពេញ, ថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១១......

**សូមគោរពជូន**

**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**
**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**
**ឯកឧត្តមរដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**
**ឯកឧត្តមរដ្ឋមន្ត្រី ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល**
**ឯកឧត្តមរដ្ឋមន្ត្រី ក្រសួងសាធារណការ និងដឹកជញ្ជូន**
**ឯកឧត្តមរដ្ឋមន្ត្រី ក្រសួងទេសចរណ៍**
**លោកជំទាវរដ្ឋមន្ត្រី ក្រសួងកិច្ចការនារី**
**ឯកឧត្តមរដ្ឋមន្ត្រី ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ**
**ឯកឧត្តមអគ្គលេខាធិការ នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា**
**ឯកឧត្តម ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជា អគ្គនាយកគយ និងរដ្ឋាករកម្ពុជា**
**ឯកឧត្តម នាយកសាលាភូមិន្ទរដ្ឋបាល**

**កម្មវត្ថុ:** សំណើសុំអញ្ជើញ **ឯកឧត្តម លោកជំទាវ** ជាសមាជិកនៃគណៈកម្មការ និងក្រុមការងារសម្រាប់អនុវត្តន៍មូលនិធិពហុភាគី និងសម្របសម្រួលអភិក្រមគ្របដណ្តប់លើវិស័យពាណិជ្ជកម្ម (Trade SWAp) ចូលរួមកិច្ចប្រជុំលើកទី ៨ នៅក្រសួងពាណិជ្ជកម្ម ។

**យោង:** លិខិតលេខ ០៦៦ សហអ ស្តីពីការកំណត់កាលបរិច្ឆេទប្រជុំ ចុះថ្ងៃទី ១៧ ខែមីនា ឆ្នាំ២០១១។

**ជូនភ្ជាប់:** របៀបវារៈនៃកិច្ចប្រជុំ និងឯកសារពិភាក្សា។

តបតាមកម្មវត្ថុខាងលើ ខ្ញុំបាទមានកិត្តិយសសូមជម្រាបជូន **ឯកឧត្តម លោកជំទាវ** មេត្តាជ្រាបថា ដើម្បីជំរុញការអនុវត្ត Trade SWAp ឱ្យមានសន្ទុះតាមការគ្រោងទុក ក្រសួងពាណិជ្ជកម្មសូមអញ្ជើញសមាជិកនៃគណៈកម្មការ និងក្រុមការងារសម្រាប់អនុវត្តន៍មូលនិធិពហុភាគី និងសម្របសម្រួលអភិក្រមគ្របដណ្តប់លើវិស័យពាណិជ្ជកម្ម (Trade SWAp) ***ចូលរួមប្រជុំពិនិត្យ និងវាយតម្លៃសម្រេចលើគម្រោងយុទ្ធសាស្ត្រមួយចំនួនដែលបានស្នើនៅក្នុងរបាយការណ៍នៃ Mid Term Review ដើម្បីឱ្យសម្រេចបានតាមការកំណត់របស់គម្រោង TDSP អនុម័តបានយ៉ាងហោចណាស់នូវគម្រោងយុទ្ធសាស្ត្រច្រើនជាង១ ក្នុង ខែ មេសា នេះ រួចស្នើមកសុំការគាំទ្រផ្នែកហិរញ្ញវត្ថុមុននឹងដាក់ជូនអនុគណៈកម្មាធិការអភិវឌ្ឍន៍ពាណិជ្ជកម្ម និងវិនិយោគទាក់ទងទៅនឹងពាណិជ្ជកម្មសម្រេច និងអនុវត្តន៍។***

ឡូត៍លេខ ១៩-៦១ វិថីក្រសួងពាណិជ្ជកម្ម (១១៣បេ), ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ, ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
*Ministry of Commerce, Lot 19-61, MOC Road (113B Road), Phum Teuk Thla, Sangkat Teuk Thla, Khand Sen Sok, Phnom Penh, Kingdom of CAMBODIA*
ទូរស័ព្ទ / ទូរសារៈ(៨៥៥)-២៣ ៨៦៦ ៤៦៩
*Phone/Facsimile: (855)-23 866 469*

កិច្ចប្រជុំនេះ នឹងប្រព្រឹត្តទៅនៅ**វេលាម៉ោង ១៤:៣០ នាទីរសៀល ថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១១ នៅសាលប្រជុំនៃក្រសួងពាណិជ្ជកម្មអាគារ ១៩-៦១ ផ្លូវ ១១៣ សង្កាត់ទឹកថ្លា ខ័ណ្ឌសែនសុខ រាជធានីភ្នំពេញ** ក្រោមអធិបតីភាព ឯកឧត្តម **ប៉ាន សូរស័ក្តិ** រដ្ឋលេខាធិការនៃក្រសួងពាណិជ្ជកម្ម និងជាប្រធាននៃគណៈកម្មការខាងលើ ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តម លោកជំទាវ** មេត្តាចាត់បញ្ជូន **ឯកឧត្តម លោកជំទាវ** ជាសមាជិកនៃគណៈកម្មការ និងក្រុមការងារសម្រាប់អនុវត្តន៍មូលនិធិពហុភាគី និងសម្របសម្រួលអភិក្រមគ្រប ដណ្តប់លើវិស័យពាណិជ្ជកម្មចូលរួមប្រជុំតាមកាលកំណត់ខាងលើ ដោយអនុគ្រោះ ។

សូម **ឯកឧត្តម លោកជំទាវ** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ អំពីខ្ញុំបាទ ។

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

*ចម្លងជូន :*

- ខុទ្ទកាល័យ ឯកឧត្តមទេសរដ្ឋមន្ត្រី
- ឯកឧត្តម ប៉ាន សូរស័ក្តិ
- ឯកឧត្តម សុខ សុភ័ក្រ្ត
- ឯកសារ-កាលប្បវត្តិ

*ទំនាក់ទំនងនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ :*

ទូរស័ព្ទ : ០១៧ ៩៧៧ ៦៩៦

: ០៩២ ៨០៨ ២៦៨

អ៊ីមែល : seng.ramy@gmail.com

mollyhean7@yahoo.com